ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២១ លេខ៩១ ត្រីមាសទី០៤ ឆ្នាំ២០២១

# រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច បទបញ្ជា សារាចរ ប្រកាស

# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៨-១២-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៩០ ស្តីពី ការតែងតាំង និង ផ្តល់ឋានៈជាទីប្រឹក្សា ឯកឧត្តម កិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី១ ក្នុងនីតិកាលទី៦ នៃរដ្ឋសភា ៣៣រូប ១១២៤១

២៨-១២-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៩១ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម **ម៉ម់ សារិន** ពី ទីប្រឹក្សាឯគឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** អនុប្រធានទី១ ព្រឹទ្ធសភា នីតិកាលទី៤ មានឋានៈស្មើ រដ្ឋមន្ត្រី ដោយសាមីខ្លួនសុំលាឈប់ ព្រោះត្រូវទទួលភារកិច្ចថ្មី ១១២៤៣


## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ


៣០-១២-២០២១ -អនុក្រឹត្យលេខ ២៧៦ អនក្រ.បក ស្តីពី ការបង្កើតគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍ សៀមរាប-អង្គរ ១១២៤៤

៣០-១២-២០២១ -អនុក្រឹត្យលេខ ២៧៧ អនក្រ.បក ស្តីពី ការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុង រាជធានីភ្នំពេញ ១១២៥២


## III~ការងារបណ្តាក្រសួង

### ១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


១៣-១២-២០២១ -ប្រកាសអន្តរក្រសួងលេខ ៨៤២ សហវ.ប្រក ស្តីពី ការតែងតាំងរជ្ជទេយ្យករបុរេប្រទាន របស់ អគ្គនាយកដ្ឋានធនធានរ៉ែ នៃក្រសួងរ៉ែ និងថាមពល ១១២៥៤

១៥-១២-២០២១ -ប្រកាសលេខ ៨៤៨ សហវ.ប្រក ស្តីពី ការតែងតាំងរជ្ជទេយ្យករចំណូល និងរជ្ជទេយ្យករ ចំណូលរងនៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តព្រះសីហនុ របស់អគ្គនាយកដ្ឋានធនធានរ៉ែ នៃ ក្រសួងរ៉ែ និងថាមពល


### ២~ទីស្តីការរដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល


៤-១-២០២១ -ប្រកាសលេខ ០០៣០ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ រួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០០៣០ រថ.អប្រក.លអ ចុះថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០២១ ១១២៥៧

៤-១-២០២១ -ប្រកាសលេខ ០០៣១ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០០៣១ រថ.អប្រក.លអ ចុះថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០២១ ១១២៦១

៤-១-២០២១ -ប្រកាសលេខ ០០៣៣ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០០៣៣ រថ.អប្រក.លអ ចុះថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០២១ ១១២៦៥

៤-១-២០២១ -ប្រកាសលេខ ០០៣៤ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០០៣៤ រថ.អប្រក.លអ ចុះថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០២១ ១១២៦៩

៤-១-២០២១ -ប្រកាសលេខ ០០៣៦ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០០៣៦ រថ.អប្រក.លអ ចុះថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០២១ ១១២៧៣

១១-១-២០២១ -ប្រកាសលេខ ០០៣៧ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០០៣៧ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០២១ ១១២៧៧

១១-១-២០២១ -ប្រកាសលេខ ០០៣៨ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
រួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០០៣៨ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០២១ ១១២៨១

១១-១-២០២១ -ប្រកាសលេខ ០០៣៩ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
រួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០០៣៩ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០២១ ១១២៨៥

១១-១-២០២១ -ប្រកាសលេខ ០០៤០ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០០៤០ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០២១ ១១២៨៩

១១-១-២០២១ -ប្រកាសលេខ ០០៤១ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០០៤១ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០២១ ១១២៩៣

១១-១-២០២១ -ប្រកាសលេខ ០០៤២ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០០៤២ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០២១ ១១២៩៧

១១-១-២០២១ -ប្រកាសលេខ ០០៤៣ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០០៤៣ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០២១ ១១៣០១

១១-១-២០២១ -ប្រកាសលេខ ០០៤៤ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០០៤៤ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០២១ ១១៣០៥

១១-១-២០២១ -ប្រកាសលេខ ០០៤៥ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០០៤៥ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០២១ ១១៣០៩

១១-១-២០២១ -ប្រកាសលេខ ០០៤៦ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០០៤៦ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០២១ ១១៣១៣

១៨-១-២០២១ -ប្រកាសលេខ ០០៤៧ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០០៤៧ រថ.អប្រក.លអ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២១ ១១៣១៧

១៨-១-២០២១ -ប្រកាសលេខ ០០៤៨ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០០៤៨ រថ.អប្រក.លអ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២១ ១១៣២១

១៨-១-២០២១ -ប្រកាសលេខ ០០៤៩ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០០៤៩ រថ.អប្រក.លអ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២១ ១១៣២៥

| | | |
|---|---|---|
| ១៨-១-២០២១ | -ប្រកាសលេខ ០០៥០ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០០៥០ រថ.អប្រក.លអ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២១ | ១១៣២៩ |
| ១៨-១-២០២១ | -ប្រកាសលេខ ០០៥១ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០០៥១ រថ.អប្រក.លអ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២១ | ១១៣៣៣ |
| ១៨-១-២០២១ | -ប្រកាសលេខ ០០៥២ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០០៥២ រថ.អប្រក.លអ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២១ | ១១៣៣៧ |
| ១៨-១-២០២១ | -ប្រកាសលេខ ០០៥៣ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០០៥៣ រថ.អប្រក.លអ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២១ | ១១៣៤១ |
| ៩-៣-២០២១ | -ប្រកាសលេខ ០០០៦ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃអាជ្ញាបណ្ណពាណិជ្ជសម្រាប់ការវេចខ្ចប់ឧស្ម័នអិល ភី ជី លេខ ០០០៦ រថ.អប្រក.អប ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០២១ | ១១៣៤៥ |
| ២-៤-២០២១ | -ប្រកាសលេខ ០០០៨ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃអាជ្ញាបណ្ណនាំចូលប្រេងឥន្ធនៈលេខ ០០០៨ រថ.អប្រក.អប ចុះថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០២១ | ១១៣៥០ |
| ១២-១១-២០២១ | -ប្រកាសលេខ ០០១៤ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់ការវេចខ្ចប់ឧស្ម័ន អិល ភី ជី លេខ ០០១៤ រថ.អប្រក.វប ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០២១ | ១១៣៥៤ |


## ៣~ទីស្តីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌


| | | |
|---|---|---|
| ៧-២-២០២២ | -ប្រកាសលេខ ០៣៨ កយ.ប្រក/២២ ស្តីពី ការបញ្ចូលក្របខ័ណ្ឌក្រឡាបញ្ជី | ១១៣៥៨ |

# ព្រះរាជក្រឹត្យ

នស/រកត/១២២១/៩៩០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឲ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៦ នាថ្ងៃព្រហស្បតិ៍ ១១រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងរចនាសម្ព័ន្ធថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភា លើកទី៦ នីតិកាលទី៦ នាថ្ងៃព្រហស្បតិ៍ ០៦រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការបោះឆ្នោតជ្រើសតាំងឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** ជាអនុប្រធានទី១រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា** នៃព្រះរាជាណាចក្រកម្ពុជា។

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំង និងផ្តល់ឋានៈជាទីប្រឹក្សា ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី១ ក្នុងនីតិកាលទី៦ នៃរដ្ឋសភា ៣៣រូប៖

| | | |
|---|---|---|
| ១- ឯកឧត្តម **អ៊ុន នីង** | មានឋានៈស្មើ **រដ្ឋមន្ត្រី** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២- ឯកឧត្តមវេជ្ជបណ្ឌិត **អ៊ុក ផល្លា** | មានឋានៈស្មើ **រដ្ឋមន្ត្រី** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៣- ឯកឧត្តម **ឡូន រាសី** | មានឋានៈស្មើ **រដ្ឋមន្ត្រី** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៤- ឯកឧត្តម **សៅ ចលក្ខណ៍** | មានឋានៈស្មើ **រដ្ឋមន្ត្រី** | |
| ៥- ឯកឧត្តម **ម៉េង ទ៉ាន់ឌី** | មានឋានៈស្មើ **រដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៦- ឯកឧត្តម **ស្រី សារឿន** | មានឋានៈស្មើ **រដ្ឋលេខាធិការ** | |
| ៧- ឯកឧត្តម **ជុំ ប៉ារីសុត** | មានឋានៈស្មើ **រដ្ឋលេខាធិការ** | |
| ៨- ឯកឧត្តម **ប្រាក់ ឈាង** | មានឋានៈស្មើ **រដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

| | | | |
|---|---|---|---|
| ៩- | ឯកឧត្តម **ហ៊ុត ប៊ុនលី** | មានឋានៈស្មើ **រដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ១០- | ឯកឧត្តមបណ្ឌិត **ផល្លា សុជាតាមុនី** | មានឋានៈស្មើ **រដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ១១- | ឯកឧត្តមបណ្ឌិត **សឹង រេត** | មានឋានៈស្មើ **រដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ១២- | ឯកឧត្តមបណ្ឌិត **ពូ សុវណ្ណា** | មានឋានៈស្មើ **រដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ១៣- | ឯកឧត្តម **ឌូន រស្មី** | មានឋានៈស្មើ **រដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ១៤- | លោកជំទាវ **ឌូន សុគន្ធី** | មានឋានៈស្មើ **រដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ១៥- | ឯកឧត្តម **ហាយ សីមី** | មានឋានៈស្មើ **រដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ១៦- | ឯកឧត្តម **ជា គឹមហាន** | មានឋានៈស្មើ **រដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ១៧- | ឯកឧត្តម **ហោង រដ្ឋា** | មានឋានៈស្មើ **រដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ១៨- | ឯកឧត្តម **អេ សុភា** | មានឋានៈស្មើ **រដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ១៩- | ឯកឧត្តម **ម៉ៅ សុចិត្រា** | មានឋានៈស្មើ **រដ្ឋលេខាធិការ** | |
| ២០- | ឯកឧត្តម **ម៉ែន ទិស្ស** | មានឋានៈស្មើ **រដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២១- | ឯកឧត្តមវេជ្ជបណ្ឌិត **ស្រេង ទ្រិន** | មានឋានៈស្មើ **រដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២២- | ឯកឧត្តមវេជ្ជបណ្ឌិត **រាន សាយ** | មានឋានៈស្មើ **រដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២៣- | ឯកឧត្តមបណ្ឌិត **ឃន ឌី** | មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២៤- | ឯកឧត្តម **សោម ចិន្តា** | មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២៥- | ឯកឧត្តម **ខ្លូង ឧត្តម** | មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២៦- | លោកជំទាវ **យ៉ន ភូមិកា** | មានឋានៈស្មើ **អគ្គនាយក** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២៧- | ឯកឧត្តម **ហាយ កុសល** | មានឋានៈស្មើ **អគ្គនាយក** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២៨- | ឯកឧត្តម **ប៉ា ឆ៉ាន់ហាន** | មានឋានៈស្មើ **អគ្គនាយក** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២៩- | ឯកឧត្តម **ឡាយ សាយ** | មានឋានៈស្មើ **អគ្គនាយក** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៣០- | លោកជំទាវ **ម៉ៅ កុសាលីន** | មានឋានៈស្មើ **អគ្គនាយក** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៣១- | លោកជំទាវ **ញ៉ៀម កុសល** | មានឋានៈស្មើ **អគ្គនាយក** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៣២- | ឯកឧត្តម **គាន តារា** | មានឋានៈស្មើ **អគ្គនាយក** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៣៣- | ឯកឧត្តម **ឃិន ទ្រីន** | មានឋានៈស្មើ **អគ្គនាយក** | បន្ថែមលើមុខងារបច្ចុប្បន្ន |

**មាត្រា២ :** លេខរៀងទី២ ក្នុងមាត្រា១ នៃព្រះរាជក្រឹត្យលេខ នស/រកត/១០១៨/១១៦៧ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងជំនួយការប្រធានគណៈកម្មការនានា ក្នុងនីតិកាលទី៦ នៃរដ្ឋសភា ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣ :** សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

នស/រកត.១២២១.៩១១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០២១*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/១២២១/៥៩១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផល នៃសម័យប្រជុំលើកដំបូងព្រឹទ្ធសភា នីតិកាលទី៤ នាថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់លទ្ធផល នៃសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៤ នាថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការជ្រើសតាំងអនុប្រធានទី១ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** បញ្ចប់មុខតំណែងឯកឧត្តម **ម៉ម់ សារិន** ពីទីប្រឹក្សាឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ុម ភា** អនុប្រធានទី១ ព្រឹទ្ធសភា នីតិកាលទី៤ មានឋានៈស្មើ **រដ្ឋមន្ត្រី** ដោយសាមីខ្លួនសុំលាឈប់ ព្រោះត្រូវទទួលភារកិច្ចថ្មី។

**មាត្រា២ :** សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរស.៥០១៥.៩១៥

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០២១*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៣២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១៦៨ អនក្រ.បក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍
- យោងផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២១-២០៣៥
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១._**

ត្រូវបានបង្កើតគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ ដែលសរសេរជាអក្សរកាត់ថា **គ.អ.ទ.ស.** ដើម្បីដឹកនាំ សម្របសម្រួល និងត្រួតពិនិត្យការអភិវឌ្ឍគោលដៅទេសចរណ៍ខេត្តសៀមរាប ដោយអនុវត្តតាមផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២១-២០៣៥ ឱ្យមានប្រសិទ្ធភាពសំដៅបង្កើនភាពប្រកួតប្រជែង និងធានាបាននូវនិរន្តរភាព។

**មាត្រា ២._**

ការគ្រប់គ្រង និងការអភិវឌ្ឍទេសចរណ៍នៅតាមតំបន់ទេសចរណ៍អាទិភាពត្រូវមានអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ គ.អ.ទ.ស.។

អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក ត្រូវបានបង្កើតឡើងតាមតំបន់ចំនួន៦ ដូចខាងក្រោម÷

**១.** តំបន់ឧទ្យានជាតិភ្នំគូលែន

**២.** តំបន់ទេសចរណ៍ជុំវិញតំបន់ការពារប្រាសាទបន្ទាយស្រី

**៣.** តំបន់បេតិកភណ្ឌអង្គរ

**៤.** តំបន់ក្រុងសៀមរាប

**៥.** តំបន់បឹងទន្លេសាប

**៦.** តំបន់ទេសចរណ៍សៀមរាបថ្មី។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន គ.អ.ទ.ស.។

សមាសភាពជាក់ស្ដែងនៃអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក ត្រូវសម្រេចដោយសេចក្ដីសម្រេចរបស់ប្រធានគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍។

ចំពោះ អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍តំបន់បេតិកភណ្ឌអង្គរ គឺជាការទទួលខុសត្រូវរបស់អាជ្ញាធរជាតិអប្សរា។

## ជំពូកទី ២

## សមាសភាព

**មាត្រា ៣._**

**គ.អ.ទ.ស.** មានសមាសភាព ដូចខាងក្រោម÷

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| - រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | អនុប្រធានអចិន្ត្រៃយ៍ |
| - រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |

| | | |
|---|---|---|
| - រដ្ឋមន្ត្រីក្រសួងបរិស្ថាន | | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម | | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងសុខាភិបាល | | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា | | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | | សមាជិក |
| - រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | | សមាជិក |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | | សមាជិក |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | សមាជិក |
| - រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | | សមាជិក |
| - រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | | សមាជិក |
| - អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | សមាជិក |
| - អគ្គស្នងការនគរបាលជាតិ | | សមាជិក |
| - មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | | សមាជិក |
| - អភិបាលនៃគណៈអភិបាលខេត្តសៀមរាប | | សមាជិកប្រចាំការ |
| - អគ្គនាយកអាជ្ញាធរជាតិអប្សរា | | សមាជិក |
| - អគ្គនាយកគ្រឹះស្ថានអង្គរ | | សមាជិក |
| - អគ្គនាយកអគ្គិសនីកម្ពុជា | | សមាជិក |
| - តំណាងក្រសួងទេសចរណ៍ | ០៣រូប | សមាជិក |
| - តំណាងអាជ្ញាធរទន្លេសាប | | សមាជិក |
| - តំណាងក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា | | សមាជិក |
| - ប្រធានលេខាធិការដ្ឋាន គ.អ.ទ.ស. | | សមាជិក |

សមាសភាពជាក់ស្តែងនៃ គ.អ.ទ.ស. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣

## តួនាទី និងភារកិច្ច

**មាត្រា ៤.-**

គ.អ.ទ.ស. មានតួនាទី និងភារកិច្ច ដូចតទៅ÷

- សម្របសម្រួល ចាត់ចែង អនុវត្តផែនការសកម្មភាពនៃផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២១-២០៣៥
- ពង្រឹងការអភិវឌ្ឍផលិតផលទេសចរណ៍ បម្រើសេចក្តីត្រូវការរបស់ភ្ញៀវទេសចរឱ្យបានសម្បូរបែប និងអាចផ្តល់បទពិសោធន៍ល្អៗ ដើម្បីជាការចងចាំដល់ភ្ញៀវទេសចរក្នុងដំណើរកម្សាន្ត
- ពង្រឹងគុណភាពផលិតផល និងសេវាកម្មទេសចរណ៍ អមជាមួយការអភិវឌ្ឍធនធានមនុស្ស និងពង្រឹងសមត្ថភាពភាគីពាក់ព័ន្ធ
- ផ្សព្វផ្សាយតំបន់/គោលដៅទេសចរណ៍របស់ខ្លួនទៅកាន់ទីផ្សារទេសចរណ៍ជាតិ និងអន្តរជាតិ
- ពិនិត្យ និងផ្តល់យោបល់លើគម្រោងវិនិយោគសាធារណៈ និងឯកជនបម្រើឱ្យការអភិវឌ្ឍវិស័យទេសចរណ៍សៀមរាប-អង្គរ ជូនស្ថាប័នមានសមត្ថកិច្ច
- ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុ ក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ
- គាំទ្រជាមូលនិធិ ដើម្បីជំរុញការអភិវឌ្ឍទេសចរណ៍នៅក្នុងតំបន់សៀមរាប-អង្គរ
- ទទួលខុសត្រូវរៀបចំផែនការអភិវឌ្ឍន៍ និងសម្របសម្រួលការអភិវឌ្ឍទេសចរណ៍ឱ្យស្របតាមផែនការអភិវឌ្ឍន៍ទេសចរណ៍ ថ្នាក់តំបន់ និងថ្នាក់ជាតិ
- ពិនិត្យ សិក្សា និងលើកសំណើធ្វើបច្ចុប្បន្នភាពផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២១-២០៣៥ ឱ្យស្របតាមសភាពការណ៍ និងការវិវត្តន៍នៃវិស័យទេសចរណ៍កម្ពុជា
- រៀបចំសូចនាករគន្លឹះសម្រាប់តាមដាន និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់ផែនការមេ
- ធ្វើរបាយការណ៍ការងារប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍
- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ជូនពីរាជរដ្ឋាភិបាល។

## ជំពូកទី៤

## កិច្ចដំណើរការការងារ

**មាត្រា ៥.-**

**គ.អ.ទ.ស.** បើកកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធានអចិន្ត្រៃយ៍តាមការប្រគល់សិទ្ធិរបស់ប្រធាន។

**គ.អ.ទ.ស.** អាចទទួលយកទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិ និងអន្តរជាតិនានាមួយចំនួនតាមការចាំបាច់។

**គ.អ.ទ.ស.** មានត្រាដោយឡែករបស់ខ្លួនក្នុងកិច្ចដំណើរការប្រចាំថ្ងៃ ដែលជាឧបសម្ព័ន្ធ២ នៃអនុក្រឹត្យនេះ។

**មាត្រា ៦.**_

**គ.អ.ទ.ស.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ អ្នកឯកទេស ឬផ្នែកឯកជនឱ្យចូលរួមប្រជុំពិគ្រោះ ពិភាក្សាយោបល់ និងសិក្សាស្រាវជ្រាវលើរាល់បញ្ហាទាំងឡាយដែលទាក់ទងនឹងក្របខណ្ឌការងាររបស់ខ្លួន។

**មាត្រា ៧.**_

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ គ.អ.ទ.ស. ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន គ.អ.ទ.ស.។

**មាត្រា ៨.**_

**គ.អ.ទ.ស.** មានអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ នៃក្រសួងទេសចរណ៍ជាលេខាធិការដ្ឋាន។ លេខាធិការដ្ឋាន អាចមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ដែលជាតំណាងមកពីរដ្ឋបាលខេត្តសៀមរាប និងតំណាងអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក។

តួនាទី ភារកិច្ច និងសមាសភាពជាក់ស្ដែងរបស់លេខាធិការដ្ឋានត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន គ.អ.ទ.ស. ។

អង្គការលេខរបស់ គ.អ.ទ.ស. ជាឧបសម្ព័ន្ធ១ នៃអនុក្រឹត្យនេះ។

## ជំពូកទី៥
## ថវិកាធនធាន

**មាត្រា ៩.**_

ថវិកាចំណាយសម្រាប់ដំណើរការរបស់លេខាធិការដ្ឋាននៃ **គ.អ.ទ.ស.** ត្រូវគាំទ្រដោយថវិកាជាតិទៅតាមលទ្ធភាពនៃថវិកាប្រចាំឆ្នាំ ក្នុងគម្រោងថវិកាកម្មវិធីរបស់ក្រសួងទេសចរណ៍។

**គ.អ.ទ.ស.** មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់នូវធនធាន និងមូលនិធិដែលបានមកពីប្រភពស្របច្បាប់ផ្សេងទៀត តាមនីតិវិធីច្បាប់ជាធរមាន សម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា ១០.**_

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១១.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ [illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ៩ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងទេសចរណ៍**

**ថោង ខុន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធ១ នៃអនុក្រឹត្យលេខ..២៧៦.......អនក្រ.បក ចុះថ្ងៃទី..៣០...ខែ..៩.....ឆ្នាំ២០២១**

**ស្តីពី**

**ការបង្កើតគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ**

**រចនាសម្ព័ន្ធនៃគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ**

**គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍**

**គណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ**

ក្រុមពិគ្រោះយោបល់ គណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារនិងការអភិវឌ្ឍតំបន់ប្រវត្តិសាស្ត្រអង្គរ

- Sub-DMO តំបន់ឧទ្យានជាតិភ្នំគូលែន
- Sub-DMO តំបន់ទេសចរណ៍ជុំវិញតំបន់ការពារប្រាសាទបន្ទាយស្រី
- Sub-DMO តំបន់អង្គរ (អាជ្ញាធរជាតិអប្សរា)
- Sub-DMO តំបន់ក្រុងសៀមរាប
- Sub-DMO តំបន់បឹងទន្លេសាប
- Sub-DMO តំបន់ទេសចរណ៍សៀមរាបថ្មី។

យន្តការស្ថាប័នគាំទ្រ

- អាជ្ញាធរជាតិអប្សរា
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- គ្រឹះស្ថានអង្គរ
- ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា (សាខាខេត្តសៀមរាប)
- សាលាជាតិវិជ្ជាជីវៈទេសចរណ៍ (សាខាខេត្តសៀមរាប)
- រដ្ឋាករស្វយ័តសំរាមខេត្តសៀមរាប
- រដ្ឋាករទឹកស្វយ័តខេត្តសៀមរាប
- ទូរគមនាគមន៍កម្ពុជា
- អគ្គិសនីកម្ពុជាប្រចាំខេត្តសៀមរាប។

**សម្គាល់÷** ICC-Angkor ជាយន្តការពិគ្រោះយោបល់ ទៅលើគម្រោងដែលពាក់ព័ន្ធនឹងតំបន់បេតិកភណ្ឌពិភពលោក (តំបន់ប្រាសាទបុរាណដ្ឋាននៅភ្នំគូលែន និងស្ទឹងសៀមរាប) និងតំបន់បេតិកភណ្ឌនានា ដើម្បីជានាគុណតម្លៃនៃរមណីយដ្ឋានអង្គរ។

**ឧបសម្ព័ន្ធ២ នៃអនុក្រឹត្យលេខ..២៧៦......អនក្រ.បក ចុះថ្ងៃទី......៣១....ខែ..ធ្នូ.....ឆ្នាំ២០២១**

**ស្តីពី**

**ការបង្កើតគណ:កម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ**

**គំរូត្រានៃគណ:កម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ**



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:....២៣៧....អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការកំណត់ផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ទំហំ ៣.២៣៩,៧ ហិកតា ស្ថិតក្នុងរាជធានីភ្នំពេញ ជាសម្បត្តិសាធារណៈរបស់រដ្ឋ

## សម្រេច

**មាត្រា ១:** ត្រូវបានកាត់ផ្ទៃដីទំហំ ៥៦.០០០ ម² (ហាសិបប្រាំមួយពាន់ម៉ែត្រក្រឡា) ស្ថិតនៅសង្កាត់ពន្សាំង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ដែលត្រូវបានកំណត់ក្នុងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការកំណត់ផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ទំហំ ៣.២៣៩,៧ ហិកតា

ស្ថិតក្នុងរាជធានីភ្នំពេញ ជាសម្បត្តិសាធារណៈរបស់រដ្ឋ ដើម្បីធ្វើអនុបយោគពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដូចមាននិយាមកាខាងក្រោមៈ

| ល.រ | អាប់ស៊ីស | អ័រដោនេ | ល.រ | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| ១ | 479752.897 | 1287860.985 | ៥ | 479849.399 | 1288150.199 |
| ២ | 479624.774 | 1287851.998 | ៦ | 479872.651 | 1288149.216 |
| ៣ | 479624.774 | 1288160.298 | ៧ | 479855.201 | 1288107.214 |
| ៤ | 479739.453 | 1288153.990 | | | |

**មាត្រា ២ :** ត្រូវបានធ្វើប្រទានកម្មផ្ទៃដីទំហំ ៥៦.០០០ ម² (ហាសិបប្រាំមួយពាន់ម៉ែត្រក្រឡា) ស្ថិតនៅសង្កាត់ពន្សាំង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ខាងលើ ជាកម្មសិទ្ធិជូនលោកស្រី រស់ ព្រីប៊ូន ដោយពន្ធ និងអាករផ្សេងៗ ជាបន្ទុករបស់រដ្ឋ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នពាក់ព័ន្ធ អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ៦ ឆ្នាំ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>**អន្លែងទទួលៈ**</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...៩៤៤...សហវ...

ប្រកាសអន្តរក្រសួង
ស្តីពី
ការតែងតាំងថ្នាក់ដឹកនាំប្រធាន
របស់អគ្គនាយកដ្ឋានធនធានរ៉ែ នៃក្រសួងរ៉ែនិងថាមពល

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

រដ្ឋមន្ត្រី
ក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្ម មាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៥១នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦.នស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ មាត្រា៤៧ នៃអនុក្រឹត្យលេខ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៧៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងរ៉ែនិងថាមពល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ស្តីពីនិតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល

## សម្រេច

**ប្រការ ១._**

ត្រូវបានតែងតាំងមន្ត្រីរាជការនៃអគ្គនាយកដ្ឋានធនធានរ៉ែ នៃក្រសួងរ៉ែនិងថាមពល មានដូចខាងក្រោមះ

| | |
|---|---|
| ១-លោកស្រី ប៊ុទ្ធិ វិឌ្ឍនី | មុខងារ អនុប្រធាននាយកដ្ឋាន ជារដ្ឋទេយ្យករបុរេប្រទាន នៅអគ្គនាយកដ្ឋានធនធានរ៉ែ នៃក្រសួងរ៉ែនិងថាមពល |
| ២-លោកស្រី លឹម ពេជ្រណ្ណលីន | មុខងារ ប្រធានការិយាល័យ ជារដ្ឋទេយ្យករបុរេប្រទានរង នៅអគ្គនាយកដ្ឋានធនធានរ៉ែ នៃក្រសួងរ៉ែនិងថាមពល |
| ៣-លោក សិទ្ធិ សាណោរ៉ាត | មុខងារ មន្ត្រី ជារដ្ឋទេយ្យករបុរេប្រទានរង នៅអគ្គនាយកដ្ឋានធនធានរ៉ែ នៃក្រសួងរ៉ែនិងថាមពល |

**ប្រការ ២._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣.**_

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ ប្រធាននាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ របស់ក្រសួងរ៉ែនិងថាមពល ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល ព្រមទាំងសាមីខ្លួនដូចប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៩ កើត ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**

**ក្រសួងរ៉ែ និងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ក្រសួងរ៉ែនិងថាមពល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០០៣០ រ៉ែ.អបែក.ប្រក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ
លេខ ០០៣០ រ៉ែ.អបែក.លអ ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០២១.

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បកចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រកចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រកចុះថ្ងៃទី០៣ខែកុម្ភៈឆ្នាំ២០១៧របស់ក្រសួងរ៉ែនិងថាមពលនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រកចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសារាចរលេខ ០១៤០ រថ.អប្រក.សរចចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ របស់លោក **ម៉ៅ សំណាង**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

## សម្រេច

**ប្រការ១.-.**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ យីហោ **ស្ថានីយប្រេងឥន្ធនៈ ព្រែកក្តាមមានជ័យ២** ស្ថិតនៅភូមិទួលងោក ឃុំកំពង់លួង ស្រុកពញាឮ ខេត្តកណ្តាល របស់លោក **ម៉ៅ សំណាង (ម្ចាស់ស្ថានីយ)**។

**ប្រការ២.-.**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-.**

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១ រថ.អប្រក.ប្រកចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោម ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរខេត្តកណ្តាល
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-.**

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមសារាចរលេខ០១៤០ រថ.អប្រក.សរចចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពលដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ នូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. ទីតាំងពោងប្រេងឥន្ធនៈ ត្រូវស្ថិតនៅចម្ងាយអប្បបរមា ៧,៥០ ម៉ែត្រ ពីរបងព្រំដីស្ថានីយ

២. ត្រូវសង់របងជាសំណាញ់ដែកក្រឡាធំ ឬជាចម្រឹងដែកការពារព័ទ្ធជុំវិញពោងឧស្ម័នឥន្ធនៈ

៣. បំពង់ខ្យល់តែមួយមិនអនុញ្ញាតឱ្យតភ្ជាប់ ប្រើសម្រាប់ចំនួនពោងលើសពីមួយឡើយ

៤. បំពង់ខ្យល់ត្រូវស្ថិតនៅចម្ងាយអប្បបរមា ២ ម៉ែត្រ ឃ្លាតពីរបងព្រំដីស្ថានីយ ហើយត្រូវមានជញ្ជាំង ឬ របងការពារការប៉ះទង្គិចណាមួយ

៥. ត្រូវបំពាក់គន្លឹះអាសន្នតាមទូចាក់ប្រេងឥន្ធនៈ

៦. ទុយោចាក់ប្រេងឥន្ធនៈមិនត្រូវមានប្រវែងលើសពី ៦ ម៉ែត្រ

៧. ត្រូវរៀបចំឱ្យមានកបំពង់ទទួលប្រេងឥន្ធនៈ

៨. ត្រូវរៀបចំឱ្យមានគំនូសសញ្ញាសម្រាប់រថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ

៩. ត្រូវមានឧបករណ៍បង្ការ និងពន្លត់អគ្គិភ័យឱ្យបានគ្រប់គ្រាន់

១០. ត្រូវរៀបចំឱ្យមានប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក។

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្ដីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរ មកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាព នៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងនិងឧស្ម័នឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្ដាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្ដាហ៍ទី១ នៃឆ្នាំបន្ទាប់មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយឱ្យមានប្រសិទ្ធិភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន អំពីហានិភ័យផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ មកអគ្គនាយកដ្ឋានប្រេងកាត នៃក្រសួងរ៉ែនិងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិចមុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាពនៃលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០០៣០.១៤.អប្រក.លអ.........ចុះថ្ងៃទី.......០៤..........ខែ...មករា......ឆ្នាំ២០២១.......... របស់ក្រសួងរ៉ែនិងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះនិងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ) ខែឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើនោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ០០.៣០.១៤.អប្រក.លអ ចុះថ្ងៃទី......០៤.....ខែ...មករា.........ឆ្នាំ២០.២១... នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការប្រធានមន្ទីររ៉ែ និងថាមពលខេត្តកណ្តាល និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.ចន្ទ.....៣រោច....ខែ..បុស្ស......ឆ្នាំជូត.ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.....០៤......ខែ..មករា.......ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលាខេត្តកណ្តាល
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០០៣១ រថ.អប្រក.ប្រក

# ប្រកាស
# ស្តីពី
# លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ

លេខ ០០៣១ រថ.អប្រក.លអ ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០២១

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិង



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាព សម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ របស់លោក **ខេង ប៊ុនគាង**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

## សម្រេច

**ប្រការ១**.-

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈដែលមានស្លាកយីហោ **ដេប៉ូតេលា ផ្សារយាយគ្រប់** ស្ថិតនៅភូមិថ្មី ឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ របស់លោក **ខេង ប៊ុនគាង (ម្ចាស់ស្ថានីយ)**។

**ប្រការ២**.-

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣**.-

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោម ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរខេត្តតាកែវ
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤**.-

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើ ឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. មិនអនុញ្ញាតឱ្យមានលំនៅដ្ឋានក្នុងបរិវេណស្ថានីយឡើយ
២. មិនអនុញ្ញាតឱ្យមានការបញ្ចូល និងលក់ចែកចាយប្រេងឥន្ធនៈក្នុងប៊ីដុងជ័រ
៣. ត្រូវរៀបចំឱ្យមានកបំពង់ទទួលប្រេងឥន្ធនៈ
៤. ត្រូវគូសគំនូសសញ្ញាសម្រាប់ចំណតរថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ



៩៧

៥. ត្រូវបំពាក់គន្លឹះអាសន្ននៅតាមទូចាក់ប្រេងឥន្ធនៈនីមួយៗ និងគន្លឹះអាសន្នរួម

៦. ត្រូវរៀបចំស្លាកសញ្ញាបម្រាមឱ្យបានគ្រប់គ្រាន់

៧. ត្រូវរៀបចំផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេងឥន្ធនៈ

៨. ត្រូវរៀបចំប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក។

**ប្រការ៥.__**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.__**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.__**

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.__**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.__**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.__**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.__**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយលេខ.០០៣១.រ.ថ:អ.បែក.ណអ............ចុះថ្ងៃទី.....០៤............ខែ..មករា.......ឆ្នាំ២០២១..................របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែ និងថាមពលដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. គួរពង្រីកក្បាលដីស្ថានីយឱ្យបានប្រវែងអប្បបរមា ២៥ម៉ែត្រ
២. មិនអនុញ្ញាតឱ្យមានបន្ទប់ស្នាក់នៅក្នុងបរិវេណស្ថានីយ
៣. ត្រូវមានកបំពង់ទទួលប្រេងឥន្ធនៈ
៤. ពោងប្រេងឥន្ធនៈមួយដាក់ប្រេងឥន្ធនៈបានតែមួយប្រភេទប៉ុណ្ណោះ



៩៧

៥. បំពង់ខ្យល់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ២ ម៉ែត្រ ពី របងព្រំដីស្ថានីយ
៦. រាងសម្រាប់ដាក់ពោងប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ២,៥០ម៉ែត្រ ពី របងព្រំដីស្ថានីយ
៧. ទូចាក់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ ម៉ែត្រ ពីអគារការិយាល័យ
៨. ទូចាក់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ ម៉ែត្រ ពី របងព្រំដីស្ថានីយ
៩. ត្រូវបំពាក់គន្លឹះអាសន្នរួម
១០. ទុយោទូចាក់ប្រេងឥន្ធនៈមិនត្រូវមានប្រវែងលើស ពី ៦ម៉ែត្រ
១១. ត្រូវមានប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក។

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្ដីណែនាំរបស់ក្រសួងរ៉ែ និងថាមពល ក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្ដល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្ដាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្ដាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាត នៃក្រសួងរ៉ែនិងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

ក្រសួងរ៉ែ និង ថាមពល

**ប្រការ១១.–**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ០០៤ រ៉ែ.ថ.ព/ប.ក.ណ.អ.........ចុះថ្ងៃទី.......១៨.........ខែ.....មករា....ឆ្នាំ២០២១...............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.–**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈ ពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើនោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ០០៤ រ៉ែ.ថ.ព/ប.ក.ណ.អ ចុះថ្ងៃទី....១៨.....ខែ...មករា........ឆ្នាំ២០២១...នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.–**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយក នៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពល ខេត្តសៀមរាប និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.ចន្ទ......៥កើត ខែ..មាឃ.....ឆ្នាំជូត.ទោស័ក ព.ស.២៥៦៤.

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..១៨...ខែ...មករា..ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលាខេត្តសៀមរាប
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
Ministry of Mines and Energy
លេខ: ០០០៦ រ៤:អប្រក.ប្រក.

# ប្រកាស
# ស្ដីពី
# លក្ខខណ្ឌនៃអាជ្ញាបណ្ណពាណិជ្ជកម្មសម្រាប់ការវេចខ្ចប់ឧស្ម័នអិល ភី ជី
**លេខ ០០០៦ រ៤:អប្រក.អ.ស.ប ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ២០២១**

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើសុំ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២០ របស់លោក ឈន ស៊ីណា

យោងតាមការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ ( ៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ( ៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ ( ៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

## សម្រេច

**ប្រការ១ .-**

ប្រកាសនេះ មានគោលបំណងកំណត់អំពីលក្ខខណ្ឌក្នុងការផ្តល់អាជ្ញាបណ្ណពាណិជ្ជកម្មសម្រាប់ការវេចខ្ចប់ឧស្ម័នអិលភីជី សម្រាប់ក្រុមហ៊ុន **គង់ ហួង អិលភីជី KONG HUONG LPG CO., LTD.** ដែលបានចុះបញ្ជីពាណិជ្ជកម្មលេខ: ០០០៣២០៩៦ និងមានទីស្នាក់ការនៅ: #១១៨៨ ផ្លូវហាណូយ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ **"អ្នកទទួលបានអាជ្ញាបណ្ណ"** ធ្វើប្រតិបត្តិការ និងថែទាំទីតាំង សម្រាប់ការវេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី ដែលមានទីតាំងស្ថិតនៅ #១១៨៨ ផ្លូវហាណូយ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

**ប្រការ២ .-**

អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាពធុរកិច្ច ដូចមានចែងក្នុងប្រការ១នៃប្រកាសនេះ (**ធុរកិច្ចដែលអនុញ្ញាត**)។ ក្នុងករណីអ្នកទទួលបានអាជ្ញាបណ្ណមានបំណងធ្វើធុរកិច្ចផ្សេងទៀត ត្រូវស្នើសុំអាជ្ញាបណ្ណ ឬ លិខិតអនុញ្ញាតដោយឡែកសម្រាប់សកម្មភាពដោយឡែក និងត្រូវស្នើសុំអាជ្ញាបណ្ណ ឬ លិខិតអនុញ្ញាតពាក់ព័ន្ធផ្សេងៗស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ៣ .-**

អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវស្នើសុំ និងទទួលបានអាជ្ញាបណ្ណ និង/ឬ លិខិតអនុញ្ញាតផ្សេងៗពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ស្របតាមការតម្រូវនៃច្បាប់ជាធរមាន ដើម្បីអនុវត្តកាតព្វកិច្ចនានាដូចមានចែងក្នុងអាជ្ញាបណ្ណនេះ។

**ប្រការ៤ .-**

ប្រកាសនេះ មានរយៈពេលសុពលភាព ស្របតាមរយៈពេលសុពលភាពនៃអាជ្ញាបណ្ណពាណិជ្ជកម្មសម្រាប់ការវេចខ្ចប់ឧស្ម័នអិល ភី ជី លេខ 000៣៦៨/ពក.អប ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០២១ និងអាចពន្យារបន្តបាន ស្របតាមអាជ្ញាបណ្ណនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៥.-**

អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនដូចតទៅ៖

១. កាតព្វកិច្ចគោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

១.១ អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវធានាអនុវត្តតាមបទដ្ឋានបច្ចេកទេសសុវត្ថិភាពរបស់ក្រសួងរ៉ែនិងថាមពល ក្នុងការសាងសង់ទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី របស់ខ្លួន។ ក្នុងករណីមិនទាន់មានបទដ្ឋានរបស់ក្រសួងរ៉ែ និង ថាមពល អ្នកទទួលបានអាជ្ញាបណ្ណត្រូវធានាអនុវត្តតាមបទដ្ឋានបច្ចេកទេសសុវត្ថិភាពដែលជាទម្លាប់អនុវត្តល្អបំផុតជាអន្តរជាតិ ក្នុងការសាងសង់ទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី។

១.២ អ្នកទទួលបានអាជ្ញាបណ្ណត្រូវគោរពតាមវិធានបទប្បញ្ញត្តិ និងនីតិវិធីនានា ដែលក្រសួងរ៉ែនិងថាមពល សម្រេចដាក់ឱ្យអនុវត្តសម្រាប់កិច្ចដំណើរការសាងសង់ និងធ្វើប្រតិបត្តិការទីតាំងសម្រាប់ការវេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី។

១.៣ អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវគោរពតាមកាតព្វកិច្ចបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិរបស់ព្រះរាជាណាចក្រកម្ពុជា។

១.៤ អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវគោរពនិងអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននានារបស់ព្រះរាជាណាចក្រកម្ពុជា។

**២. កាតព្វកិច្ចក្នុងការរៀបចំទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី**

២.១ អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវធ្វើការរៀបចំទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី នៅលើទីតាំងដែលបានកំណត់។

២.២ អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវធ្វើការរៀបចំទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី តាមផែនការគំនូសប្លង់បច្ចេកទេសរៀបចំសុវត្ថិភាពទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី ដែលមានការយល់ព្រមពីក្រសួងរ៉ែនិងថាមពល។ ក្នុងករណីមានការកែប្រែផែនការគំនូសប្លង់ផ្សេងៗ អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវស្នើសុំការយល់ព្រមពីក្រសួងរ៉ែនិងថាមពល មុនចាប់ផ្តើមការរៀបចំ។

២.៣ អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរៀបចំទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជីរបស់ខ្លួន។

២.៤ អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវផ្តល់នូវរបាយការណ៍អំពីវឌ្ឍនភាពក្នុងការរៀបចំទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជីនេះ ជាប្រចាំត្រីមាស នៅក្នុងសប្តាហ៍ទី១នៃត្រីមាសបន្ទាប់។

២.៥ អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់នូវរាល់ឧបទ្ទវហេតុ និងគ្រោះថ្នាក់ទាំងឡាយ ដែលកើតឡើងក្នុងអំឡុងពេលដំណើរការរៀបចំទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី របស់ខ្លួន។

២.៦ អ្នកទទួលបានអាជ្ញាបណ្ណ មិនត្រូវប្រគល់ ឬ ផ្ទេរសិទ្ធិបង្កើតទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី នេះឱ្យអ្នកដទៃដោយគ្មានការអនុញ្ញាតពីក្រសួងរ៉ែនិងថាមពលឡើយ។

៣. កាតព្វកិច្ចផ្សេងទៀត

៣.១ អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវផ្តល់ប្លង់បច្ចេកទេសជាក់ស្តែងនៃសំណង់ទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី ក្រោយសាងសង់រួចជាស្ថាពរមួយច្បាប់សម្រាប់តម្កល់នៅអគ្គនាយកដ្ឋានប្រេងកាត។

៣.២ អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យឧស្ម័នអិល ភី ជី ដែលបាននាំចូល និងលក់ចែកចាយជាប្រចាំត្រីមាស នៅក្នុងសប្តាហ៍ទី១នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំក្នុងខែមករានៃឆ្នាំបន្ទាប់មកក្រសួងរ៉ែនិងថាមពល។

៣.៣ អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់នូវរាល់ឧបទ្ទវហេតុ និងគ្រោះថ្នាក់ទាំងឡាយដែលកើតឡើងក្នុងអំឡុងពេលប្រតិបត្តិការទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី របស់ខ្លួន។

៣.៤ អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែនិងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ដើម្បីឱ្យការគ្រប់គ្រងទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី មានប្រសិទ្ធភាពខ្ពស់។

**ប្រការ ៦.-**

ដោយទីតាំងវេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី បានសាងសង់រួចហើយនោះ ម្ចាស់ទីតាំងត្រូវរៀបចំកែសម្រួលទៅតាមលក្ខខណ្ឌដែលតម្រូវដោយក្រសួងរ៉ែ និងថាមពល និងត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតដំណើរការទីតាំងវេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជីពីក្រសួងរ៉ែ និងថាមពល មុននឹងបន្តដំណើរការ។

**ប្រការ ៧.-**

ដោយប្រកាសរួមលេខ ១២៨ សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ពុំទាន់មានចែងពីកម្រៃសេវាសាធារណៈដែលត្រូវបង់ សម្រាប់អាជ្ញាបណ្ណពាណិជ្ជកម្មសម្រាប់វេចខ្ចប់(បញ្ចូល) ឧស្ម័នឥន្ធនៈ អ្នកទទួលបានអាជ្ញាបណ្ណនឹងត្រូវតម្រូវឱ្យបង់កម្រៃសេវាសាធារណៈក្រោយមានការចែងពីកម្រៃសេវានេះ។

**ប្រការ ៨.-**

អាជ្ញាបណ្ណនេះ នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌ ប្រសិនបើអ្នកទទួលបានអាជ្ញាបណ្ណមិនបានចាប់ផ្តើមសាងសង់ទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជីនេះ ក្នុងរយៈពេល១២ (ដប់ពីរ) ខែ គិតចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ ឬ អ្នកទទួលបានអាជ្ញាបណ្ណបានប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសជូនធូរនឹងលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងប្រកាសនេះ។

ប្រការ ៩.-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាតអគ្គាធិការ ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីររ៉ែនិងថាមពលរាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន **គង់ ហួង អិលភីជី KONG HUONG LPG CO., LTD.** ត្រូវអនុវត្តប្រកាសនេះ តាមភារកិច្ចទទួលបន្ទុករៀងៗខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះទៅ។

ថ្ងៃអង្គារ ១១រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០០០៨ រ៉ែ.អប្រេក.ប្រក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃអាជ្ញាបណ្ណនាំចូលប្រេងឥន្ធនៈ
## លេខ ០០០៨ រ៉ែ.អប្រេក.ឥប ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០២១

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៧/១២១៣ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាស់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១ សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨ សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹង

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ប្រកាសរួមលេខ១៤៥១ សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់

- បានឃើញសំណើសុំចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ របស់ក្រុមហ៊ុន ប្លូ អូសិន គ្រុប ឯ.ក
- យោងតាមការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

## សម្រេច

**ប្រការ១ .-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌក្នុងការផ្តល់អាជ្ញាបណ្ណនាំចូលប្រេងឥន្ធនៈ សម្រាប់ **ក្រុមហ៊ុន ប្លូ អូសិន គ្រុប ឯ.ក** (BLUE OCEAN GROUP CO., LTD.) ដែលបានបង្កើតឡើងស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងបានចុះបញ្ជីពាណិជ្ជកម្មលេខ ០០០៣២១៩៥ និងមានទីស្នាក់ការនៅ Exchange Square លេខ១៣០៥ ជាន់ទី១៣ ផ្លូវលេខ១០៦ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ **(អ្នកទទួលបានអាជ្ញាបណ្ណ)** ធ្វើការនាំចូលប្រេងឥន្ធនៈ ដើម្បីផ្គត់ផ្គង់និងចែកចាយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២ .-**

អ្នកទទួលបានអាជ្ញាបណ្ណត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាពធុរកិច្ច ដូចមានចែងក្នុងប្រការ១នៃប្រកាសនេះ **(ធុរកិច្ចដែលអនុញ្ញាត)**។ ក្នុងករណីអ្នកទទួលបានអាជ្ញាបណ្ណមានបំណងធ្វើធុរកិច្ចផ្សេងទៀត ត្រូវស្នើសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតដោយឡែកសម្រាប់សកម្មភាពដោយឡែកនិងត្រូវស្នើសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតពាក់ព័ន្ធផ្សេងៗស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ៣ .-**

អ្នកទទួលបានអាជ្ញាបណ្ណត្រូវស្នើសុំ និងទទួលបានអាជ្ញាបណ្ណ និង/ឬលិខិតអនុញ្ញាតផ្សេងៗពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ស្របតាមលក្ខខណ្ឌតម្រូវនៃច្បាប់ជាធរមាន ដើម្បីអនុវត្តកាតព្វកិច្ចនានាដូចមានចែងក្នុង អាជ្ញាបណ្ណនេះ។

**ប្រការ៤ .-**

អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវមានកំពង់ផែទទួល និងមណ្ឌលសន្និធិប្រេងឥន្ធនៈច្បាស់លាស់ មុនធ្វើការនាំចូលប្រេងឥន្ធនៈ។

**ប្រការ៥ .-**

ប្រកាសនេះមានរយៈពេលសុពលភាព ស្របតាមរយៈពេលសុពលភាពនៃអាជ្ញាបណ្ណនាំចូលប្រេងឥន្ធនៈ លេខ.០០០៨.រ៤.អប្រេ.ក.អ.ប...... ចុះថ្ងៃទី....០៧...ខែ..មេសា....ឆ្នាំ.២០២១ និងអាចពន្យារបន្តបានស្របតាមអាជ្ញាបណ្ណនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ៦ .-**

ក្រសួងរ៉ែនិងថាមពលសម្រេចដកហូត ឬព្យួរអាជ្ញាបណ្ណក្នុងករណីណាមួយខាងក្រោម៖

ក- អ្នកទទួលបានអាជ្ញាបណ្ណខកខានមិនបានចាប់ផ្តើម ឬ មិនបានបំពេញកាតព្វកិច្ចការងារតាមពេលវេលាកំណត់ដូចមានចែងក្នុងអាជ្ញាបណ្ណនាំចូលប្រេងឥន្ធនៈ និងប្រកាសនេះ។

ខ- អ្នកទទួលបានអាជ្ញាបណ្ណខកខានមិនបានបំពេញកាតព្វកិច្ចហិរញ្ញវត្ថុនានាបានត្រឹមត្រូវតាមការតម្រូវស្របតាមបទប្បញ្ញត្តិជាធរមាន ហើយបន្តខកខានការអនុវត្តកាតព្វកិច្ចនេះ ក្នុងរយៈពេល ១៤ (ដប់បួន) ថ្ងៃ ក្រោយទទួលបានលិខិតជូនដំណឹងអំពីការខកខាននៃការបំពេញកាតព្វកិច្ចនេះពីក្រសួងរ៉ែនិងថាមពល ឬស្ថាប័នមានសមត្ថកិច្ច។

គ- អ្នកទទួលបានអាជ្ញាបណ្ណបានប្រព្រឹត្តល្មើសធ្ងន់ធ្ងរលើបទប្បញ្ញត្តិនិងលក្ខខណ្ឌនៃអាជ្ញាបណ្ណ និងប្រកាសនេះ ហើយអ្នកទទួលបានអាជ្ញាបណ្ណខកខានមិនបានកែតម្រូវឱ្យមានភាពអនុលោមវិញតាមការតម្រូវ ឬសេចក្តីណែនាំរបស់ក្រសួងរ៉ែនិងថាមពល។

ឃ- អ្នកទទួលបានអាជ្ញាបណ្ណមិនមានភាពអនុលោមតាមច្បាប់ បទដ្ឋានបច្ចេកទេស និងបទប្បញ្ញត្តិជាធរមាននានារបស់ព្រះរាជាណាចក្រកម្ពុជា ហើយអ្នកទទួលបានអាជ្ញាបណ្ណខកខានមិនបានកែតម្រូវឱ្យមានភាពអនុលោមវិញតាមការតម្រូវ ឬសេចក្តីណែនាំរបស់ក្រសួងរ៉ែនិងថាមពល។

ង- ដើម្បីផលប្រយោជន៍សាធារណៈ ឬសន្តិសុខនៃព្រះរាជាណាចក្រកម្ពុជា តម្រូវឱ្យធ្វើការដកហូតអាជ្ញាបណ្ណទាំងមូល ឬដកហូតសិទ្ធិខ្លះនៃអាជ្ញាបណ្ណ ស្របតាមច្បាប់និងបទប្បញ្ញត្តិនានាជាធរមាន។

**ប្រការ៧ .-**

ការផុតសុពលភាពអាជ្ញាបណ្ណ ឬការដកហូតអាជ្ញាបណ្ណ មិនប៉ះពាល់ដល់កាតព្វកិច្ចដែលអាចត្រូវបានបង្គរទុកនៅមុនពេលផុតសុពលភាពអាជ្ញាបណ្ណ ឬមុនកាលបរិច្ឆេទដកហូតអាជ្ញាបណ្ណ និងមិនប៉ះពាល់ដល់ការបន្តការទទួលខុសត្រូវនិងកាតព្វកិច្ចរបស់អ្នកទទួលបានអាជ្ញាបណ្ណ ដែលត្រូវបំពេញបន្តក្រោយពីការផុតសុពលភាព ឬដកហូតអាជ្ញាបណ្ណ ដូចមានចែងក្នុងប្រកាសនេះឡើយ។

**ប្រការ៨ .-**

ការពន្យារពេលអនុវត្ត ឬខកខានមិនទាន់បានអនុវត្តដោយក្រសួងរ៉ែនិងថាមពលនូវសិទ្ធិ អំណាច បុព្វសិទ្ធិ ឬវិធានការកែលម្អចែងក្នុងប្រកាសនេះ មិនត្រូវបានចាត់ទុកជាការបាត់បង់ ឬការបោះបង់មិនអនុវត្តដោយក្រសួងរ៉ែនិងថាមពលនូវសិទ្ធិ អំណាច បុព្វសិទ្ធិ ឬវិធានការកែលម្អទាំងនោះឡើយ។ ការអនុវត្តតែផ្នែកណាមួយនៃសិទ្ធិ អំណាច បុព្វសិទ្ធិ ឬវិធានការកែលម្អដែលមានចែងក្នុងប្រកាសនេះ មិនត្រូវបានចាត់ទុកថាជាការលើកលែងនូវផ្នែកផ្សេងទៀតនៃសិទ្ធិ អំណាច បុព្វសិទ្ធិ ឬវិធានការកែលម្អ ទាំងនោះឡើយ។

**ប្រការ៩ ._**

អ្នកទទួលបានអាជ្ញាបណ្ណ ត្រូវអនុវត្តកាតព្វកិច្ចហិរញ្ញវត្ថុស្របតាមបទប្បញ្ញត្តិជាធរមាន។

**ប្រការ១០ ._**

អ្នកទទួលបានអាជ្ញាបណ្ណត្រូវចាត់តាំងនិងអនុវត្តវិធានការតាមការតម្រូវរបស់ក្រសួងរ៉ែនិងថាមពល ក្នុងការរៀបចំផែនការនិងត្រៀមលក្ខណៈសម្រាប់ពេលគ្រោះអាសន្ន។

**ប្រការ១១ ._**

អ្នកទទួលបានអាជ្ញាបណ្ណត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យប្រភេទប្រេងឥន្ធនៈដែលគ្រោងនាំចូល ប្រចាំឆ្នាំ និងទិន្នន័យប្រេងឥន្ធនៈដែលបាននាំចូល និងលក់ចែកចាយប្រចាំត្រីមាស នៅក្នុងសប្តាហ៍ទី១នៃ ត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ១២._**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត និងប្រធានក្រុមហ៊ុន **ប៊្លូ អូសិន គ្រុប ឯ.ក** ត្រូវអនុវត្ត ប្រកាសនេះ តាមភារកិច្ចទទួលបន្ទុករៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ៩រោច ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០០១៤ រ៉ែ.អ.ប្រក.

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព សម្រាប់ការបេចខ្ចប់ឧស្ម័ន អិល ភី ជី

លេខ ០០១៤ រ៉ែ.អ.ប្រក.វប ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០២១

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញលិខិតស្នើសុំ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ របស់ក្រុមហ៊ុន ខេអិនអេចស៊ី អេនធើនាស៊ែ
- យោងតាមការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ ( ៥១ ) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ( ៨៥៥ ) ២៣ ២១៩ ៥៧៤ ទូរសារ ( ៨៥៥ ) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

## សម្រេច

**ប្រការ១ .-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌក្នុងការផ្តល់វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់ការវេចខ្ចប់ឧស្ម័នអិល ភី ជី ដែលមានទីតាំងស្ថិតនៅភូមិទួលសំពៅ សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ របស់ក្រុមហ៊ុន **ខេអិនអេចស៊ី អេនជីនារីង** (KNHC ENGINEERING Co., Ltd.) ដែលបានចុះបញ្ជីពាណិជ្ជកម្មលេខ ០០០០៤៧១៣ ដែលមានទីស្នាក់ការនៅផ្លូវលេខ១០១៩ ភូមិបន្លាស្អិត សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ (**ម្ចាស់ទីតាំងវេចខ្ចប់**)។

**ប្រការ២ .-**

ម្ចាស់ទីតាំងវេចខ្ចប់ត្រូវតាំងបង្ហាញវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់ការវេចខ្ចប់ឧស្ម័នអិល ភី ជី នៅទីតាំងដែលងាយមើលឃើញក្នុងទីតាំងវេចខ្ចប់ឧស្ម័នអិល ភី ជី របស់ខ្លួន។

**ប្រការ៣ .-**

ម្ចាស់ទីតាំងវេចខ្ចប់ត្រូវរៀបចំទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី របស់ខ្លួននូវចំណុចបច្ចេកទេសជាបន្តបន្ទាប់ក្នុងរយៈពេលសុពលភាពនៃវិញ្ញាបនបត្រនេះ តាមគំនូសប្លង់បច្ចេកទេសរៀបចំសុវត្ថិភាពទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល)ឧស្ម័នអិល ភី ជី ដោយមានបញ្ជាក់ពីចម្ងាយសុវត្ថិភាពពីគ្រឿងបង្គុំមួយទៅគ្រឿងបង្គុំមួយទៀត ឱ្យបានច្បាស់លាស់ និងត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសក្នុងការរៀបចំទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល) ឧស្ម័នអិល ភី ជី។

**ប្រការ៤ .-**

ម្ចាស់ទីតាំងវេចខ្ចប់ត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៥.-**

ម្ចាស់ទីតាំងវេចខ្ចប់ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណពាណិជ្ជកម្មសម្រាប់ការវេចខ្ចប់ឧស្ម័នអិល ភី ជី នេះ ក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃបន្ទាប់ពីបញ្ចប់ការសាងសង់ទីតាំងវេចខ្ចប់របស់ខ្លួន មកក្រសួងរ៉ែនិងថាមពល ។

**ប្រការ៦ .-**

ម្ចាស់ទីតាំងវេចខ្ចប់ត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ មកក្រសួងរ៉ែ និងថាមពល



ក្រសួងរ៉ែ និង ថាមពល

៥៤

មុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល) ឧស្ម័នអិល ភី ជី ជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃប្រតិបត្តិការនៃការវេចខ្ចប់(បញ្ចូល) ឧស្ម័នអិល ភី ជី នេះ។

**ប្រការ៧ .-**

ម្ចាស់ទីតាំងវេចខ្ចប់ត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យបរិមាណឧស្ម័នអិល ភី ជី ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំក្នុងខែមករានៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពល។

**ប្រការ៨ .-**

ម្ចាស់ទីតាំងវេចខ្ចប់ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែនិងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ដើម្បីឱ្យការគ្រប់គ្រងទីតាំងសម្រាប់វេចខ្ចប់(បញ្ចូល) ឧស្ម័នអិល ភី ជី មានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩ .-**

ម្ចាស់ទីតាំងវេចខ្ចប់ត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃទីតាំងវេចខ្ចប់ឧស្ម័នអិល ភី ជី របស់ខ្លួន។

**ប្រការ១០ .-**

ម្ចាស់ទីតាំងវេចខ្ចប់ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពល រយៈពេល ១(មួយ)ខែ យ៉ាងតិច មុនថ្ងៃបញ្ឈប់ដំណើរការទីតាំងរបស់ខ្លួនជាស្ថាពរ។

**ប្រការ១១ .-**

ប្រកាសនេះមានរយៈពេលសុពលភាព ស្របតាមរយៈពេលសុពលភាពនៃវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់ការវេចខ្ចប់ឧស្ម័ន អិល ភី ជី លេខ ០០១៤.១៦.៥ ប្រក.វ.ប.... ចុះថ្ងៃទី.១២...ខែវិច្ឆិកា...ឆ្នាំ.២០២១ របស់ក្រសួងរ៉ែនិងថាមពល និងអាចពន្យារបន្តបាន ស្របតាមវិញ្ញាបនបត្រនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២ .-**

ក្នុងករណីទីតាំងសម្រាប់ការវេចខ្ចប់នេះ ផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ (ដប់ពីរ) ខែ ឬ



៥៤

ប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់ការវេចខ្ចប់ឧស្ម័នអិល ភី ជី លេខ.០០១៤.រ៉ែ.អបគ.វប.... ចុះថ្ងៃទី.១២.ខែ.វិច្ឆិកា...ឆ្នាំ ២០២១....... នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពលរាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ខេអិនអេចស៊ី អេនជីនារីង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.សុក្រ...៨កើត.....ខែ..កត្តិក..ឆ្នាំឆ្លូវ...ត្រីស័ក..ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..១២ ខែ.វិច្ឆិកា. ឆ្នាំ.២០២១

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**ស៊ុយ-សែម**

**<u>កន្លែងទទួល៖</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានីភ្នំពេញ
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ :០១៣៨ ករយ.ឧប្រក/២២

# ប្រកាស

**ស្តីពី**

**ការបញ្ចូលក្របខណ្ឌក្រឡាបញ្ជី**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៥/០១៩ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥ ស្តីពីការបង្កើតរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១០៥៨ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការផ្ទេររាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមលិខិតលេខ ៦៨៨/២១/របវត ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ របស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- យោងតាមលិខិតលេខ ៦៩៧/២១/របវត ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ របស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

## សម្រេច

**ប្រការ១ .-**

ត្រូវបានបញ្ចូលក្របខណ្ឌក្រឡាបញ្ជីនៃក្រសួងយុត្តិធម៌ នូវសិស្សក្រឡាបញ្ជីជំនាន់ទី៧ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ចំនួន **១១៧រូប** ចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ តទៅ និងចាត់ឲ្យចុះធ្វើកម្មសិក្សានៅតាមអង្គការតុលាការ និងអង្គការអយ្យការនានា ដូចមានរាយនាមខាងក្រោម ៖

| ល.រ | គោត្តនាម និងនាម | ថ្ងៃខែឆ្នាំកំណើត | ប្រភេទក្របខណ្ឌ | អង្គភាព | ផ្សេង ៗ |
|---|---|---|---|---|---|
| ក.តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល | | | | | |
| ១ | លោកស្រី សុខ សេរីសោភ័ណ្ឌ | ១០-១០-១៩៩២ | ក.៣.៤ | តុលាការកំពូល | អតីតភាពជាមន្ត្រីរាជការ |
| ២ | លោក អែម ប៊ុនណាត | ១៥-០៥-១៩៨៨ | ខ.១.៦ | តុលាការកំពូល | |
| ៣ | លោក លី ថៃវ៉ាត់ | ២៥-១០-១៩៩៨ | ខ.១.៦ | តុលាការកំពូល | |
| ៤ | លោក ហ៊ុយ ហេងឡុង | ០៩-០១-១៩៩៨ | ខ.១.៦ | តុលាការកំពូល | |
| ៥ | លោក ជុំ សម្បត្តិ | ២៤-១០-១៩៩៧ | ខ.១.៦ | តុលាការកំពូល | |
| ៦ | លោក យេ សទ្ធា | ១០-០១-១៩៩៧ | ខ.១.៦ | តុលាការកំពូល | |
| ៧ | លោកស្រី សាយ វិច្ឆិកា | ០៧-១១-១៩៩៤ | ខ.១.៦ | តុលាការកំពូល | |
| ៨ | លោក នី ចាន់ចាវ | ១៧-០៨-១៩៩៣ | ខ.១.៦ | តុលាការកំពូល | |
| ៩ | លោកស្រី ឯក ពិសី | ០២-០៥-១៩៩៥ | ខ.១.៦ | តុលាការកំពូល | |
| ១០ | លោកស្រី ចឹម ពិសី | ១៣-០៤-១៩៩៥ | ខ.១.៦ | តុលាការកំពូល | |
| ១១ | លោក លឹម សុបុណ្ណមី | ១៩-១០-២០០០ | ខ.១.៦ | តុលាការកំពូល | |
| ១២ | លោកស្រី សាយ សុម៉ាលីទីន | ០៧-០៦-១៩៩៤ | ខ.១.៦ | តុលាការកំពូល | |
| ១៣ | លោក ឌឹត ថៃគុណ | ០៩-១០-១៩៩៦ | ខ.១.៦ | តុលាការកំពូល | |
| ១៤ | លោក សឿន វណ្ណឌី | ១៥-០៤-១៩៩៨ | ខ.១.៦ | តុលាការកំពូល | |
| ១៥ | លោក ដាំ ពន្លក | ១០-១១-១៩៩៩ | ខ.១.៦ | តុលាការកំពូល | |
| ខ.សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ | | | | | |
| ១៦ | លោកស្រី ហេង ស៊ីចាន់ | ២៣-០៣-១៩៩៧ | ខ.១.៦ | សាលាឧទ្ធរណ៍ | |
| ១៧ | លោក ព្រំ គឿន | ០៧-០៥-១៩៩២ | ខ.១.៦ | សាលាឧទ្ធរណ៍ | |
| ១៨ | លោកស្រី សុវណ្ណ ថាវឌ្ឍន៍ | ៣០-០១-១៩៩៩ | ខ.១.៦ | សាលាឧទ្ធរណ៍ | |
| ១៩ | លោកស្រី ណាត ស្រីនុច | ០១-០៣-១៩៩៨ | ខ.១.៦ | មហាអយ្យការ | |
| ២០ | លោកស្រី ភ៉ា ដានីត | ១៨-០៣-១៩៩៨ | ខ.១.៦ | មហាអយ្យការ | |
| គ.សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ | | | | | |
| ២១ | លោកស្រី សាយ មុន្នី | ០៧-០៣-១៩៩៦ | ខ.១.៦ | សាលាឧទ្ធរណ៍ | |

| | | | | | | |
|---|---|---|---|---|---|---|
| ២២ | លោកស្រី | ហ៊្សូ កត្រា | ០៥-១២-១៩៩៩ | ខ.១.៦ | សាលាឧទ្ធរណ៍ | |
| ២៣ | លោកស្រី | ព្រុំ កត្តលីកា | ១៤-១១-១៩៩៨ | ខ.១.៦ | សាលាឧទ្ធរណ៍ | |
| ២៤ | លោកស្រី | ផាង ស្រីពេជ្រ | ០៩-០២-២០០០ | ខ.១.៦ | មហាអយ្យការ | |
| ២៥ | លោក | ម៉េង សេងហាវ | ០២-០២-១៩៩៤ | ខ.១.៦ | មហាអយ្យការ | |
| ឃ.សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង | | | | | | |
| ២៦ | លោក | ស៊ុំ ចាន់តារាពិទូរ្យ | ០៣-០៨-១៩៩៨ | ខ.១.៦ | សាលាឧទ្ធរណ៍ | |
| ២៧ | លោកស្រី | កន ម៉ូនីតា | ០៤-០៦-១៩៩៨ | ខ.១.៦ | សាលាឧទ្ធរណ៍ | |
| ២៨ | លោក | ផន សីហា | ១៥-០១-១៩៩៨ | ខ.១.៦ | សាលាឧទ្ធរណ៍ | |
| ២៩ | លោកស្រី | បេ ឡានី | ១៥-១២-១៩៩២ | ខ.១.៦ | មហាអយ្យការ | |
| ៣០ | លោក | វណ្ណៈ រស្មី | ១៣-០៥-១៩៩៤ | ខ.១.៦ | មហាអយ្យការ | |
| ង.សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ | | | | | | |
| ៣១ | លោកស្រី | គួច វ៉ូសរីម៉ី | ១៦-០៤-១៩៩៩ | ខ.១.៦ | សាលាឧទ្ធរណ៍ | |
| ៣២ | លោក | ប៉ែន ផាន់នី | ១១-០៦-១៩៩១ | ខ.១.៦ | សាលាឧទ្ធរណ៍ | |
| ៣៣ | លោកស្រី | ថន បញ្ញា | ១៥-០៩-១៩៩៤ | ខ.១.៦ | សាលាឧទ្ធរណ៍ | |
| ៣៤ | លោកស្រី | ប្រាក់ ចេនឡា | ០១-០១-១៩៩៦ | ខ.១.៦ | សាលាឧទ្ធរណ៍ | |
| ៣៥ | លោក | សាន សីហា | ២៥-០១-១៩៩០ | ខ.១.៦ | សាលាឧទ្ធរណ៍ | |
| ៣៦ | លោកស្រី | តេង ណារី | ០៦-០៥-១៩៩៤ | ខ.១.៦ | មហាអយ្យការ | |
| ៣៧ | លោក | ផាង លីហៀង | ០៦-០៦-១៩៩៤ | ខ.១.៦ | មហាអយ្យការ | |
| ច.សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ | | | | | | |
| ៣៨ | លោកស្រី | រុន សុខហេង | ១៥-០៣-១៩៩៨ | ខ.១.៦ | សាលាដំបូង | |
| ៣៩ | លោកស្រី | ឧត្តម ស្រីគួចកន្និដ្ឋា | ២២-០៥-១៩៩៨ | ខ.១.៦ | សាលាដំបូង | |
| ៤០ | លោកស្រី | រ៉ែ ច័ន្ទរស្មី | ២៥-០៨-១៩៩៧ | ខ.១.៦ | សាលាដំបូង | |
| ៤១ | លោក | កាល់ ធិកា | ១៥-០៤-១៩៨៧ | ក.៣.៣ | សាលាដំបូង | អតីតភាពជាមន្ត្រីរាជការ |
| ៤២ | លោក | សែម ស័ក្តិស៊ីនសុវណ្ណៈ | ០៥-០៥-១៩៩៧ | ខ.១.៦ | អយ្យការ | |
| ឆ.សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង | | | | | | |
| ៤៣ | លោកស្រី | វឿន ចន្ធី | ២៤-០៨-១៩៩៧ | ខ.១.៦ | សាលាដំបូង | |
| ៤៤ | លោក | សោម លាភ | ២១-០៦-១៩៩៧ | ខ.១.៦ | សាលាដំបូង | |
| ៤៥ | លោកស្រី | ចាន់ មួយលីម | ០៧-១០-១៩៩៩ | ខ.១.៦ | អយ្យការ | |
| ៤៦ | លោកស្រី | សាន វិច្ឆិកា | ០៤-១១-១៩៩៨ | ខ.១.៦ | អយ្យការ | |
| ជ.សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកំពង់ចាម | | | | | | |
| ៤៧ | លោកស្រី | ទេព ពិសី | ០១-១២-១៩៩១ | ខ.១.៦ | សាលាដំបូង | |

ស៊ ៩

| | | | | | |
|---|---|---|---|---|---|
| ៤៨ | លោកស្រី ស្រ៊ិន បូរ៉ានី | ០៥-០៦-១៩៩៥ | ខ.១.៦ | សាលាដំបូង | |
| ៤៩ | លោក ឡុង ប៉ោហេង | ២៩-០៥-១៩៩៦ | ខ.១.៦ | អយ្យការ | |
| ឈ.សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង | | | | | |
| ៥០ | លោកស្រី រី ស៊ីណា | ២៨-០៤-១៩៩៩ | ខ.១.៦ | សាលាដំបូង | |
| ៥១ | លោកស្រី ផុន ផាន្នី | ២៩-០៩-១៩៩៨ | ខ.១.៦ | សាលាដំបូង | |
| ៥២ | លោក ខាន់ សុខា | ១០-០៦-១៩៩៩ | ខ.១.៦ | អយ្យការ | |
| ញ.សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ | | | | | |
| ៥៣ | លោក ហ៊ុយ សុខលីន | ១៣-១១-១៩៩៨ | ខ.១.៦ | សាលាដំបូង | |
| ៥៤ | លោក ប្រាក់ មករា | ០៥-០១-១៩៩៣ | ខ.១.៦ | សាលាដំបូង | |
| ៥៥ | លោក ផល់ សុភ័ក្ររិទ្ធ | ១៧-០៦-១៩៩៨ | ខ.១.៦ | អយ្យការ | |
| ដ.សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកំពង់ធំ | | | | | |
| ៥៦ | លោកស្រី សេម ស្រីណំ | ០៦-០៧-១៩៩៦ | ខ.១.៦ | សាលាដំបូង | |
| ៥៧ | លោក ម៉ុក ព្រះ | ០៥-០៧-១៩៩៣ | ខ.១.៦ | សាលាដំបូង | |
| ឋ.សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកំពត | | | | | |
| ៥៨ | លោក គយ ពិសិដ្ឋ | ១៧-០៥-១៩៨៩ | ខ.១.៦ | សាលាដំបូង | |
| ៥៩ | លោក ហ៊ិន សុវិសាល | ១៦-០៣-១៩៨៩ | ក.៣.៤ | សាលាដំបូង | អតីតភាពជាមន្ត្រីរាជការ |
| ៦០ | លោក ប៊ុន ផារ័ត្នពេជ្រដារ៉ូ | ០១-១១-១៩៩៩ | ខ.១.៦ | សាលាដំបូង | |
| ឌ.សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកណ្ដាល | | | | | |
| ៦១ | លោកស្រី ស ធីតា | ០១-០៨-១៩៩៩ | ខ.១.៦ | សាលាដំបូង | |
| ៦២ | លោកស្រី ប៊ិល លក្ខិណា | ១៦-០៣-១៩៩៨ | ខ.១.៦ | អយ្យការ | |
| ឍ.សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកោះកុង | | | | | |
| ៦៣ | លោក ឡុញ ឈី | ២១-០៩-១៩៩៩ | ខ.១.៦ | សាលាដំបូង | |
| ៦៤ | លោក ម៉េង ចាន់ថេង | ០៣-០៤-១៩៩៤ | ខ.១.៦ | សាលាដំបូង | |
| ៦៥ | លោក ពេជ្រ ផល្លីន | ១៥-០១-១៩៩៨ | ខ.១.៦ | អយ្យការ | |
| ណ.សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តក្រចេះ | | | | | |
| ៦៦ | លោកស្រី ទឹម ធារី | ០៩-១០-១៩៩៨ | ខ.១.៦ | អយ្យការ | |
| ត.សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តមណ្ឌលគិរី | | | | | |
| ៦៧ | លោក ម៉ក់ វឿន | ០៥-០២-១៩៩៨ | ខ.១.៦ | សាលាដំបូង | |
| ៦៨ | លោកស្រី សំអាត សុខៃ | ១៧-០៤-១៩៩៦ | ខ.១.៦ | សាលាដំបូង | |
| ៦៩ | លោក គាំ ប្រុស | ០២-០៥-១៩៩៨ | ខ.១.៦ | សាលាដំបូង | |
| ៧០ | លោកស្រី ភាព សុខី | ២៤-០៧-១៩៩៥ | ខ.១.៦ | អយ្យការ | |

| | | | | | | |
|---|---|---|---|---|---|---|
| ច.សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ | | | | | | |
| ៧១ | លោក | តាំង ឆៃហេង | ០៤-០៧-១៩៩៥ | ឧ.១.៦ | សាលាដំបូង | |
| ៧២ | លោក | អ៊ឹង ម៉េងហួន | ២០-០៣-២០០០ | ឧ.១.៦ | សាលាដំបូង | |
| ៧៣ | លោក | សូ ផល្លា | ២១-០១-១៩៩៥ | ឧ.១.៦ | អយ្យការ | |
| ទ.សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តព្រះវិហារ | | | | | | |
| ៧៤ | លោក | ធិន ធុល | ០៩-១០-១៩៩២ | ឧ.១.៦ | សាលាដំបូង | |
| ៧៥ | លោក | លឿង គីមហេង | ០៥-០៥-១៩៩៨ | ឧ.១.៦ | សាលាដំបូង | |
| ធ.សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តព្រៃវែង | | | | | | |
| ៧៦ | លោកស្រី | ស៊ុន ដាឡែន | ១២-១២-១៩៩៧ | ឧ.១.៦ | សាលាដំបូង | |
| ន.សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់ | | | | | | |
| ៧៧ | លោក | អេង ជីម៉េង | ១៥-១០-១៩៩៣ | ឧ.១.៦ | សាលាដំបូង | |
| ៧៨ | លោក | សារ៉ុម ស៊ីប៉ាវ | ១២-០៦-១៩៩៥ | ឧ.១.៦ | សាលាដំបូង | |
| ៧៩ | លោក | ហ៊ិន សំណាង | ០៤-១០-២០០០ | ឧ.១.៦ | សាលាដំបូង | |
| ប.សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តរតនគិរី | | | | | | |
| ៨០ | លោក | ថេង ជួងវេង | ០១-០៦-១៩៩៦ | ឧ.១.៦ | សាលាដំបូង | |
| ៨១ | លោក | ពៅ រស្មី | ២៦-០៩-១៩៩៦ | ឧ.១.៦ | សាលាដំបូង | |
| ៨២ | លោក | ម៉ៅ សុខា | ០៥-១០-១៩៩៣ | ឧ.១.៦ | សាលាដំបូង | |
| ៨៣ | លោក | ណោ វត្ថា | ២០-០៨-១៩៩៤ | ឧ.១.៦ | អយ្យការ | |
| ផ.សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តសៀមរាប | | | | | | |
| ៨៤ | លោកស្រី | វ៉ន ច័ន្ទសុភា | ២៩-០៣-១៩៩៩ | ឧ.១.៦ | សាលាដំបូង | |
| ៨៥ | លោក | ឡាយ ចាន់ណា | ០១-០៤-១៩៩៦ | ឧ.១.៦ | អយ្យការ | |
| ព.សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ | | | | | | |
| ៨៦ | លោក | គន់ ដារិទ្ធ | ១៧-១១-១៩៩៨ | ឧ.១.៦ | សាលាដំបូង | |
| ៨៧ | លោក | អៀម សុផាត | ២០-០២-២០០០ | ឧ.១.៦ | សាលាដំបូង | |
| ៨៨ | លោកស្រី | ហុង ស៊ីមួយ | ២០-១០-២០០០ | ឧ.១.៦ | សាលាដំបូង | |
| ៨៩ | លោក | ចាន់ សុធា | ១០-០៨-១៩៩៥ | ឧ.១.៦ | អយ្យការ | |
| ភ.សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តស្ទឹងត្រែង | | | | | | |
| ៩០ | លោក | ស៊ាន គីមហេង | ០២-០៥-១៩៩៨ | ឧ.១.៦ | សាលាដំបូង | |
| ៩១ | លោក | យឹម ឧត្តម | ០៣-០៦-១៩៩៤ | ឧ.១.៦ | សាលាដំបូង | |

| | | | | | | |
|---|---|---|---|---|---|---|
| ៩២ | លោក | ខេង សុងលី | ១៨-០២-១៩៩៥ | ខ.១.៦ | អយ្យការ | |
| ម.សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តស្វាយរៀង | | | | | | |
| ៩៣ | លោកស្រី | ហ៊ីម ស៊ីមអូន | ២៤-០៥-១៩៩៧ | ខ.១.៦ | សាលាដំបូង | |
| ៩៤ | លោកស្រី | ផុន ផ្លង | ១០-១១-១៩៩៨ | ខ.១.៦ | សាលាដំបូង | |
| ៩៥ | លោក | យ៉ាន់ លីន | ០៧-០៨-១៩៩៨ | ខ.១.៦ | សាលាដំបូង | |
| ៩៦ | លោក | អូន វ៉ាន់ឌី | ០៩-១១-១៩៩៥ | ខ.១.៦ | សាលាដំបូង | |
| ៩៧ | លោក | ផាត វណ្ណ | ២៥-១០-១៩៩៥ | ខ.១.៦ | អយ្យការ | |
| យ.សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តតាកែវ | | | | | | |
| ៩៨ | លោក | សំ គុម្ភះ | ០៨-១២-១៩៩៦ | ខ.១.៦ | សាលាដំបូង | |
| ៩៩ | លោកស្រី | ភ័ក្ត សុនី | ១២-០១-១៩៩៨ | ខ.១.៦ | សាលាដំបូង | |
| ១០០ | លោក | ឡាយ សេងហុង | ០៥-០២-១៩៩៨ | ខ.១.៦ | សាលាដំបូង | |
| ១០១ | លោក | ឡុច ប៉ាលី | ១៧-០៤-១៩៩៦ | ខ.១.៦ | អយ្យការ | |
| រ.សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ | | | | | | |
| ១០២ | លោក | ស៊ឹង វិសាល | ០៥-០៣-១៩៩៥ | ខ.១.៦ | សាលាដំបូង | អតីតភាពជាមន្ត្រីរាជការ |
| ១០៣ | លោក | រិន សុខមាន | ១១-០៤-១៩៩៩ | ខ.១.៦ | សាលាដំបូង | |
| ១០៤ | លោក | ស្រៀង វឌ្ឍនា | ១១-១២-១៩៩៨ | ខ.១.៦ | សាលាដំបូង | |
| ១០៥ | លោកស្រី | ឡុក គិមលូ | ០៥-០៤-១៩៩៨ | ខ.១.៦ | សាលាដំបូង | |
| ល.សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តប៉ៃលិន | | | | | | |
| ១០៦ | លោក | ព្រំ មុន្នី | ០៩-០៨-១៩៩៦ | ខ.១.៦ | សាលាដំបូង | |
| ១០៧ | លោកស្រី | ទីវ បញ្ញា | ១២-១០-១៩៩៨ | ខ.១.៦ | សាលាដំបូង | |
| ១០៨ | លោក | ផែង ភារដ្ឋ | ១១-០៧-១៩៩៣ | ខ.១.៦ | សាលាដំបូង | |
| វ.សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ | | | | | | |
| ១០៩ | លោក | ហុក ហុងឡេង | ២១-០១-១៩៩៨ | ខ.១.៦ | សាលាដំបូង | |
| ១១០ | លោកស្រី | ស៊ឹម ចាន់វនាថ | ០៦-០១-១៩៩៧ | ខ.១.៦ | សាលាដំបូង | |
| ១១១ | លោក | យ៉ាង មករា | ២៩-០១-១៩៩៩ | ខ.១.៦ | សាលាដំបូង | |
| ១១២ | លោក | ស៊ុំ ដុល្លា | ១២-០១-១៩៩៥ | ខ.១.៦ | សាលាដំបូង | |
| ស.សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកែប | | | | | | |
| ១១៣ | លោកស្រី | សៅ សុភ័ក្ត្រ | ០៨-០២-១៩៩៨ | ខ.១.៦ | សាលាដំបូង | |
| ១១៤ | លោក | ឡេង តារ៉ា | ០៤-០២-១៩៩៦ | ខ.១.៦ | សាលាដំបូង | |
| ១១៥ | លោកស្រី | អ៊ិន ស្រីនៀង | ១២-១១-២០០០ | ខ.១.៦ | សាលាដំបូង | |
| ១១៦ | លោក | ខន បុល | ១៥-០៣-១៩៩២ | ខ.១.៦ | អយ្យការ | |

| | | | | | |
|---|---|---|---|---|---|
| ១១៧ | លោកស្រី ព្រី ម៉ាណែត | ០៧-០៦-១៩៩៨ | ខ.១.៦ | អយ្យការ | |

**ប្រការ២ .-**

សាមីជនដែលមានឈ្មោះក្នុងប្រការ១ ត្រូវធ្វើកម្មសិក្សារយៈពេល **១២ខែ** ចំពោះក្រឡាបញ្ជីកម្មសិក្សា ដែលមានអតីតភាពជានិស្សិត និងរយៈពេល **៦ខែ** ចំពោះក្រឡាបញ្ជីកម្មសិក្សា ដែលមានអតីតភាពជាមន្ត្រីរាជការក្របខណ្ឌចាស់ នៅតាមអង្គការតុលាការ និងអង្គការអយ្យការនានា ក្នុងប្រភេទក្របខណ្ឌបៀវត្សដូចមានចែងក្នុងប្រការ១ នឹងត្រូវទទួលបានប្រាក់បំណាច់មុខងារ និងប្រាក់វិភាជន៍គ្រួសារតាមគោលការណ៍កំណត់របស់រដ្ឋ ដូចក្រឡាបញ្ជីដែលកំពុងបំពេញការិយកម្ម។ កម្មសិក្សានេះ មិនត្រូវយកជាការបានទេ បើកាលណាសាមីជនអាក់ខានមកធ្វើកម្មសិក្សាសរុបលើសពី **៣០ថ្ងៃ**។

**ប្រការ៣ .-**

ប្រធានអង្គការតុលាការ និងប្រធានអង្គការអយ្យការនីមួយៗ ដែលទទួលបន្ទុកកម្មសិក្សា ត្រូវធ្វើរបាយការណ៍ និងព្រឹត្តិបត្រវាយតម្លៃលើក្រឡាបញ្ជីកម្មសិក្សាម្នាក់ៗ តាមគំរូដូចបានភ្ជាប់មកជាមួយ ផ្ញើមកក្រសួងជាសម្ងាត់ នៅពេលកម្មសិក្សាត្រូវបានបញ្ចប់។

**ប្រការ៤ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងយុត្តិធម៌ អគ្គនាយកនៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍វិស័យយុត្តិធម៌ ប្រធានអង្គការតុលាការ និងប្រធានអង្គការអយ្យការ ដែលទទួលបន្ទុកកម្មសិក្សា ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៦កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី